| កិច្ចតែងការ | |
|---|---|
| មុខវិជ្ជា | សិក្សាសង្គម |
| ប្រធានបទ | គំនូរ និងសកម្មភាពកសាង |
| ចំណងជើងមេរៀន | សត្វត្រឡោកដូង ដកស្រង់ចេញពី "រឿង តើអ្នកពូកែអី?" ។ |
| កម្រិត | ៤ ឆ្នាំ, មធ្យម ៣០ នាទី ។ |
| គោលបំណង | -កុមារបង្ហាញការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព។<br>-កុមារស្គាល់ពណ៌។ |
| បំណិនសម្បទា | គូរ និងផាត់ពណ៌រូបគំនូរបានត្រឹមត្រូវ, ចលនាដៃបានល្អ។ |
| ចរិយាសម្បទា | ស្រឡាញ់ចូលចិត្ត អំណត់ ព្យាយាម ច្នៃប្រឌិត។ |
| គ្រូបង្រៀន<br>(ផលិតសម្ភារឧបទេស) | ប្រមូលត្រឡោកដូង បោះពុម្ពក្រដាសរូបភាព ឬលាបពណ៌លើត្រឡោកដូងដោយខ្លួនអ្នក ដើម្បីផ្តល់ជាគំនិតទៅកាន់កុមារ និងធ្វើម្សៅពណ៌។ |
| កុមារ | អង្គុយជាក្រុមតូចៗ ដែលមានសមាជិកពី ៤ ឬ ៥នាក់។ |
| ការរៀបចំ | បែងចែកម្សៅពណ៌ទៅក្នុងប្រអប់តូចៗ និងសម្ភារសម្រាប់គូរ និងផាត់ពណ៌ឱ្យបានគ្រប់គ្រាន់សម្រាប់កុមារម្នាក់ៗ។ |

| សកម្មភាពគ្រូបង្រៀន | សកម្មភាពសិស្ស |
|---|---|
| ១. ប្រាប់កុមារថាពួកគេនឹងផាត់ពណ៌ជារូបសត្វនៅលើត្រឡោកដូង។<br>២. បង្ហាញរូបភាពគំរូដែលអ្នកបានធ្វើជារូបសត្វអ្វីម៉្យាង។<br>៣. សួរកុមារថាសត្វណាដែលពួកគេចង់ផាត់ពណ៌។<br>៤. សួរពួកគេអំពីពណ៌ដែលមួយណាដែលពួកគេ | ១. ចូរស្តាប់អ្នកគ្រូ/លោកគ្រូ។<br>២. ចូរជ្រើសរើសសត្វដែលអ្នកចង់ផាត់ពណ៌។<br>ជ្រើសរើសរូបណាដែលអ្នកអាចគូរបាន។<br>៣. ចូរចែកថ្នាំពណ៌ជាមួយមិត្តរួមក្រុមទាំងមូល។<br>៤. ដំបូង ផាត់ត្រឡោកដូងទាំងមូលសិន បន្ទាប់មកបន្ថែមចំណុចលម្អិត ដូចជាភ្នែក ត្រចៀក ជើង ជាដើម។ |

| | |
|---|---|
| ត្រូវការ និងស្រឡាញ់។<br>៥. បែងចែកកុមារជាក្រុម ដែលមានសមាជិកពី ៤-៥ នាក់ អាស្រ័យលើពណ៌ដែលពួកគេត្រូវការ និងស្រឡាញ់។<br>៦. ឱ្យពួកគេផាត់ពណ៌លើត្រឡោកដូងទាំងមូល និងផាត់ពណ៌ភ្នែក ត្រចៀក ជើង ។ល។<br>៧. ប្រសិនបើអ្នកពុំមានម្សៅពណ៌ខ្មៅនិងពណ៌ស កុមារអាចហែក/កាត់រង្វង់ ពីក្រដាសពណ៌ស គូរភ្នែក និងបិទលើត្រឡោកដូង។<br>៨. នៅពេលរង់ចាំថ្នាំពណ៌ឱ្យស្ងួតល្អ និយាយអំពីសត្វផ្សេងៗដែលកុមារបានគូរ និងផាត់ពណ៌។<br>៩. សរសេរឈ្មោះសត្វលើក្ដារខៀន។ | ៥. ចូរសរសើរកិច្ចការគ្នាទៅវិញទៅមក។<br> |